# ជំនឿសំឡឹងមើលទៅព្រះ **faith toward God**

Hebrews 6:1-3

១ ដូច្នេះ ចូរឲ្យយើងឈប់ ខាងឯសេចក្ដីបឋមសិក្សានៃព្រះបន្ទូលព្រះគ្រីស្ទ
ហើយខំឲ្យបានជឿនទៅមុខ ដរាបដល់ពេញខ្នាតចុះ មិនត្រូវតាំងសេចក្ដីដើម
នោះជាថ្មីឡើងវិញ ដូចជាសេចក្ដីប្រែចិត្តចេញពីការស្លាប់ និងសេចក្ដីជំនឿជឿ
ដល់ព្រះ ២ ហើយនិងសេចក្ដីបង្រៀនពីបុណ្យជ្រមុជ ការដាក់ដៃ សេចក្ដីរស់ពី
ស្លាប់ឡើងវិញ និងសេចក្ដីជំនុំជំរះកាត់ទោសដល់អស់កល្បជានិច្ចនោះឡើយ
៣ បើសិនជាព្រះទ្រង់អនុញ្ញាតឲ្យ នោះយើងរាល់គ្នានឹងធ្វើការនោះឯង
៤ ដ្បិតឯពួកអ្នកដែលបានភ្លឺម្តង ទាំងភ្លក់អំណោយទាននៃស្ថានសួគ៌ ក៏បាន
ចំណែកនៃព្រះវិញ្ញាណបរិសុទ្ធ ៥ ហើយភ្លក់ព្រះបន្ទូលដ៏ល្អនៃព្រះ និងការឫទ្ធិ
បារមីរបស់បរលោកនាយ ៦ រួចធ្លាក់ទៅវិញ នោះគ្មានផ្លូវណានឹងនាំឲ្យគេប្រែ
ចិត្តម្តងទៀតទេ ដោយព្រោះគេបានឆ្កាងព្រះរាជបុត្រានៃព្រះ ខាងឯខ្លួនគេរួច
ទៅហើយ ព្រមទាំងធ្វើឲ្យទ្រង់ហាលមុខនៅកណ្តាលជំនុំផង ៧ ដ្បិតដីណា
បានបៀមទឹកភ្លៀង ដែលធ្លាក់មកជាញយៗ រួចបង្កើតជាបន្លែមានប្រយោជន៍
ដល់អ្នកដែលភ្ជួររាស់ នោះបានទទួលព្រះពរហើយ ៨ តែដីណាដែលបង្កើត
សុទ្ធតែបន្លា និងអញ្ចាញវិញ ដីនោះត្រូវបោះបង់ចោលចេញ ក៏ជិតនឹងត្រូវ
បណ្តាសាហើយ លុះដល់ចុងបំផុតនឹងត្រូវដុតចោលផង។

## ១- ហេតុអ្វីបានជំនឿសំខាន់

## Why is Faith Important

Hebrews 11:6 but without faith it is impossible to please God. តែបើឥតមានសេចក្ដីជំនឿទេ នោះមិនអាចនឹងគាប់ដល់ព្រះហឫទ័យព្រះបានឡើយ ដ្បិតអ្នកណាដែលចូលទៅឯព្រះ នោះត្រូវតែជឿថា មានព្រះមែន ហើយថា ទ្រង់ប្រទានរង្វាន់ដល់អស់អ្នកដែលស្វែងរកទ្រង់។

## ២- អ្វីទៅជាប្រភពនៃសេចក្ដីជំនឿ

## What is the Source of Faith

John 3:27 យ៉ូហានឆ្លើយថា គ្មានមនុស្សណាអាចនឹងទទួលអ្វីបានទេ លើកតែបានប្រទានពីស្ថានសួគ៌មកឲ្យប៉ុណ្ណោះ- Faith is a gift from God ។

## ៣- ធ្វើដូចម្ដេចដើម្បីអោយជំនឿមានដំណើរការបាន

## How Faith is Activated

Romans 12:3 ៣ ដ្បិតខ្ញុំនិយាយនឹងមនុស្សទាំងអស់ក្នុងពួកអ្នករាល់គ្នា ដោយព្រះគុណដែលទ្រង់បានផ្តល់មកខ្ញុំថា ចូរគិតបែបឲ្យមានគំនិតនឹងធឹង តាមខ្នាតនៃសេចក្ដីជំនឿ ដែលព្រះបានចែកមកអ្នករាល់គ្នានិមួយៗ កុំឲ្យមានគំនិតខ្ពស់ លើសជាងគំនិតដែលគួរគប្បីឲ្យគិតនោះឡើយ God gives us faith, everyone has a measure of faith ។